បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

# ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

## ប.ស.ស. ឆ្នាំទី ១០
## លេខ ២៨ ឆ្នាំ២០២០




ធានាសន្តិសុខប្រាក់ចំណូល
រួមចំណែកកាត់បន្ថយភាពក្រីក្រ
លើកកម្ពស់សុវិភាពសង្គម

ទំនាក់ទំនងបន្ទាន់
**១២៨៦**
**២៤ម៉ោង/៧ថ្ងៃ**

# ព្រឹត្តិបត្រព័ត៌មាន
# ប.ស.ស.



## មាតិកា


០១ ប្រជាកសិករ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង ក្រុមគ្រូពេទ្យ...០១

០២ រដ្ឋសភា អនុម័ត សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម......០២

០៣ ច្បាប់ស្តីពី របបសន្តិសុខសង្គម ត្រូវបានដាក់ឱ្យប្រើប្រាស់ជា.......០៣

០៤ រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា..........០៤

០៥ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករ......០៦

០៦ បន្ទាប់ពីវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តការងារ ផ្នែកថៃ.......០៨

០៧ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ អ្នកស្លាប់ដែលបណ្តាលមកពីគ្រោះ...១០

០៨ ពិធីទទួលទានអំបុក ដើម្បីចូលរួមការពារជាតិ សាសនា និង.......១២

០៩ បេឡាជាតិសន្តិសុខសង្គម គ្រោងនឹងដាក់ឱ្យដំណើរការរបប.......១៤

១០ ឯកឧត្តម ស៊ុំ សោភ័ណ អញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការ.....១៧

១១ ម្ចាស់សហគ្រាស គ្រឹះស្ថាន និងតំណាងសហគ្រាសថ្មី ចូលរួម.....១៨

១១ នៅពេលឆាប់ៗខាងមុខនេះ បេឡាជាតិសន្តិសុខសង្គម.............១៩

១២ ក្រុមអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជួបពិភាក្សា.......២១

១៣ មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម (កម្ពុជា) ០១រូប ចូល.....២២

១៤ មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម ចូលរួមវគ្គបណ្តុះ...........២៤

១៥ មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម កម្ពុជា ៤រូប ចូលរួមវគ្គ....២៥

១៦ មន្ត្រី ប.ស.ស. កម្ពុជាចំនួន ២រូប ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី..២៧

១៧ មន្ត្រី បេឡាជាតិសន្តិសុខសង្គម កម្ពុជាចំនួន ១៣រូប ទៅបំពេញ ..២៨

១៨ ក្រុមអាហារទាំង៣ពណ៌នេះ សំខាន់យ៉ាងណាខ្លះចំពោះ...........២៩

១៩ កម្រងពាក្យអប់រំ ដកស្រង់ពីព្រះពុទ្ធសាសនា ប្រមូលរៀប..........៣០









## រចនាសម្ព័ន្ធព្រឹត្តិបត្រ

**ឯកឧត្តម អ៊ុក សមវិទ្យា**
**នាយក ប.ស.ស.**

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក ឃុន វិចិត្រ |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា រ៉ាត់ ម៉ាលីកា |
| | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| | លោក លឹម តក់ |
| ផ្នែកការីកុំព្យូទ័រ | លោក ប៊ុត ស៊ីម |
| | លោក យង់ សុខន |
| | លោក អ៊ុង ស៊ីឡឿ |



# ប្រជាកសិករ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង ក្រុមគ្រូពេទ្យ ប្រមាណ ជាង ១ ២០០ នាក់ ទទួលព្រះរាជអំណោយ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងសំណេះសំណាល សួរសុខទុក្ខ និងព្រះរាជទាន ព្រះរាជអំណោយ ជូនដល់ប្រជាកសិករ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង ក្រុមគ្រូពេទ្យ នៅភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ប្រមាណជាង ១ ២០០នាក់ នាព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៩៕






# រដ្ឋសភា អនុម័ត សេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម

នៅថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម នាសម័យប្រជុំលើកទី៣ នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការី ជាតំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា តាមគោលការណ៍សាមគ្គីធម៌ និងសមធម៌សង្គម ដោយបញ្ចូលនូវផ្នែកប្រាក់សោធន បន្ថែមលើផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ ដែលកំពុងអនុវត្ត សម្រាប់បុគ្គលស្ថិតក្នុងវិស័យសាធារណៈ និងនិយោជិតក្នុងវិស័យឯកជន។

ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីនេះ ត្រូវបានរៀបចំស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល ដោយបង្កើតនូវយន្តការអភិបាលកិច្ចថ្មី និងមានប្រសិទ្ធភាព ដែលបែងចែកតួនាទីក្នុងកម្រិតគោលនយោបាយ និងកម្រិតយុទ្ធសាស្ត្រ កម្រិតបញ្ញត្តិករ និងកម្រិតប្រតិបត្តិករ ក្នុងគោលដៅបង្កើតនូវភាពរឹងមាំ តម្លាភាព និងប្រតិតុល្យការ រវាងប្រតិបត្តិការ ការគ្រប់គ្រង និងការត្រួតពិនិត្យ ធានានូវចីរភាព និងការពារបានជាអតិបរមានូវផលប្រយោជន៍របស់អ្នកទទួលផលពីរបបសន្តិសុខសង្គម ដែលជាសសរស្តម្ភដ៏សំខាន់មួយនៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា៕








# ច្បាប់ស្តីពី របបសន្តិសុខសង្គម ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការហើយ

ច្បាប់ស្តីពី របបសន្តិសុខសង្គម ដែលរាជរដ្ឋាភិបាលបានរៀបចំបញ្ជូនទៅរដ្ឋសភា ហើយរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ដែលព្រឹទ្ធសភាបានពិភាក្សាចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់ទាំងស្រុង កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ត្រូវបានព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងទ្រង់ឡាយព្រះហស្តលេខាប្រកាស ឱ្យប្រើនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

ច្បាប់ស្តីពី របបសន្តិសុខសង្គម មានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឱ្យមានសមធម៌ និងសាមគ្គីធម៌ និងលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះ មាន១១ជំពូក និងចែកចេញជា១០៧មាត្រា៕









# រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ (ILO) បានចុះហត្ថលេខារួមគ្នាបន្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា រយៈពេល២ឆ្នាំទៀត

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) និងអង្គការអន្តរជាតិខាងការងារ(ILO) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា " ស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា សម្រាប់ឆ្នាំ២០២០-២០២២ "នៅសណ្ឋាគារសាន់វេ នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ដោយគ្របដណ្តប់លើវិស័យកាត់ដេរសម្លៀកបំពាក់ និងវាយនភណ្ឌ សម្ភារៈ និងកាបូបធ្វើដំណើរ។ នេះជាអនុស្សរណៈលើកទី៦ហើយ ក្នុងការបន្តទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងកិច្ចសហការកាន់តែប្រសើរ ដើម្បីឱ្យស្របទៅនឹងការវិវត្តន៍នៃស្ថានការបច្ចុប្បន្ន និងទៅអនាគត។

អនុស្សរណៈនៃការយោគយល់គ្នារវាងភាគីទាំបីខាងលើនេះ លើកទី១ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ដើម្បីបន្តអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេសដែលមានឈ្មោះថា "ការធានាថាលក្ខខណ្ឌការងារក្នុងវិស័យវាយនភណ្ឌ និងសម្លៀកបំពាក់នៅកម្ពុជា សមស្របតាមបទដ្ឋានការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងស្របតាមច្បាប់ស្តីពីការងារកម្ពុជា"សម្រាប់រយៈពេល ២ឆ្នាំ ហើយគម្រោងនេះ ត្រូវបានផ្លាស់ប្តូរឈ្មោះទៅជា "គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា" រហូតមកដល់បច្ចុប្បន្ន។






**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បញ្ជាក់ថា៖ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ក្នុងការចូលរួមចំណែកក្នុងការធានានូវសិទ្ធិការងារ និងលក្ខខណ្ឌការងារល្អប្រសើរសម្រាប់បងប្អូនកម្មករនិយោជិត ដោយផ្អែកលើភាពជោគជ័យនៃការអនុវត្តគម្រោងនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបន្តអនុស្សរណៈ នៃការយោគយល់គ្នាក្នុងការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា សម្រាប់ឆ្នាំ២០២០-២០២២ ។ ការសម្រេចនេះ គឺធ្វើឡើងដើម្បីឆ្លើយតបទៅនឹងផែនការសហប្រតិបត្តិការ និងសមាហរណកម្មរបស់គម្រោងរោងចក្រកាន់តែប្រសើរ ជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងបេសកកម្មលើកកម្ពស់ "លក្ខខណ្ឌការងារក្នុងវិស័យវាយនភណ្ឌ និងសម្លៀកបំពាក់នៅកម្ពុជា សមស្របតាមបទដ្ឋានការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងស្របតាមច្បាប់ស្តីពីការងារកម្ពុជា"។








**ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លើកឡើងថា៖ តាមរយៈការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្មជាមួយនឹងបទដ្ឋានការងារ បានប្រែក្លាយកេរ្តិ៍ឈ្មោះរបស់កម្ពុជាទៅជាប្រទេសដែលឈានមុខគេក្នុងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ និងបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសគំរូសម្រាប់ប្រទេសមួយចំនួនយកទៅធ្វើបទពិសោធន៍សម្រាប់អនុវត្ត និងរៀនសូត្រតាម។ ការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្ម ជាមួយនឹងបទដ្ឋានការងារ ក៏បានបង្កើនទំនុកចិត្តដល់អ្នកបញ្ជាទិញម៉ាកយីហោល្បីៗក្នុងការដាក់បន្ថែមការបញ្ជាទិញផលិតផល សម្លៀកបំពាក់ និងវាយនភណ្ឌនៅកម្ពុជាពីមួយឆ្នាំ ទៅមួយឆ្នាំកាន់តែច្រើនឡើង

**លោក ឧកញ៉ា វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជាឱ្យដឹងថា៖ "សមាគមរោងចក្រកាត់ដេរ នឹងបន្តធ្វើការជាមួយរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរក្សាការផលិត សុវត្ថិភាពការងារ និងការងារប្រកបដោយចីរភាព សម្រាប់ជាកម្លាំងពលកម្មរបស់កម្ពុជារបស់យើង" ។

**លោក** Grame Buckley នាយកការិយាល័យអង្គការ ILO ប្រចាំប្រទេសកម្ពុជា ឡាវ និងថៃ បានកត់សម្គាល់ថា៖ "ដោយធ្វើការជាមួយរាជរដ្ឋាភិបាល និងសមាគមរោងចក្រកាត់ដេរ យើងនឹងរួមគ្នាលើកកម្ពស់ការងារសមរម្យ សម្រាប់កម្មកររាប់រយរាប់ពាន់នាក់ ជាពិសេសស្ត្រី ហើយក៏ជួយកម្មករនិយោជិត ក្នុងការអភិវឌ្ឍជំនាញថ្មីៗ អាជីវកម្ម ដើម្បីទទួលប្រាក់ចំណេញកាន់តែច្រើនជាងមុន និងក្រុមគ្រួសារពួកគេ ឱ្យចាកផុតពីភាពក្រីក្រ"៕



# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតបង្ហាញពីលទ្ធផលការងារសម្រេចបានក្នុងនព្វមាស ឆ្នាំ២០១៩ និងទិសដៅការងារអនុវត្តន៍បន្ត

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកនិងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក នៃ ប.ស.ស. ក្នុងកិច្ចប្រជុំស្តីពីលទ្ធផលការងារសម្រេចបានក្នុងនព្វមាស ឆ្នាំ២០១៩ និងទិសដៅការងារអនុវត្តន៍បន្ត របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិតនៃបេឡាជាតិសន្តិសុខសង្គមនៅសាលប្រជុំ ប.ស.ស. នៅរាជធានីភ្នំពេញ បានថ្លែងថា៖ គ្រោះថ្នាក់ចរាចរណ៍នៅតែជាកង្វល់របស់រាជរដ្ឋាភិបាល បើទោះបីមានការសហការរវាងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក ជាមួយនឹងក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដែលមានតួនាទីសំខាន់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិតស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក និងប្រឡងយកប័ណ្ណបើកបរនៅក្នុងនព្វមាស ឆ្នាំ២០១៩ នេះ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ ក្នុងការចូលរួមអនុវត្តផែនការសកម្មភាព " សុវត្ថិភាពចរាចរណ៍ផ្លូវគោកចំពោះកម្មករនិយោជិត" ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បេឡាជាតិសន្តិសុខសង្គម និងក្រសួង ស្ថាប័ន អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដែលជាដៃគូសហការ ត្រូវតែបង្កើននូវកិច្ចសហការក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បន្តទៀតធ្វើយ៉ាងណា ចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ឱ្យនៅកម្រិតទាបបំផុត។





បើយោងតាមរបាយការណ៍ បានបង្ហាញថា៖ ក្នុងនព្វមាស ឆ្នាំ២០១៩ នេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក បាន៖

- ប្រជុំផ្សព្វផ្សាយអប់រំច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ជូនដល់កម្មករនិយោជិត បានចំនួន២៤៣លើកដោយមានអ្នកចូលរួមសរុបចំនួន ១៦ ៣១២នាក់
- រៀបចំការប្រឡងយកប័ណ្ណបើកបរ ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតបានចំនួន ២៣លើក អ្នកចូលរួមសរុបចំនួន ១ ២១៦នាក់ ប្រឡងជាប់ជាស្ថាពរចំនួន ១ ០៧៤នាក់ (ប្រភេទ "ខ" ចំនួន ៥៧២ប័ណ្ណ ជាប់ចំនួន ៤៩៥ប័ណ្ណ និងប្រភេទ "ឃ២" ចំនួន ៦៤៤ប័ណ្ណ ជាប់ចំនួន ៥៧៩ប័ណ្ណ)
- ផ្ដល់ប័ណ្ណបើកបរ ជូនដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត បានចំនួន ២០លើក អ្នកទទួលប័ណ្ណបើកបរចំនួន ១ ២៦២នាក់ (ប្រភេទ "ខ" ចំនួន ៥៤៥ ប័ណ្ណ និងប្រភេទ "ឃ២" ចំនួន ៧១៧ ប័ណ្ណ)
- រៀបចំផលិតប័ណ្ណមូលនិធិសមធម៌សុខាភិបាល ជូនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចំនួន ៣ ០៥៦ប័ណ្ណ
- ផ្ដល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ជូនដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត បានចំនួន ១៨លើក អ្នកទទួលប័ណ្ណចំនួន ៨៧៨ប័ណ្ណ

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើនេះ ប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ១២ កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១៩ ដោយមានវត្តមានចូលរួមពីសំណាក់ **ឯកឧត្តម លោកជំទាវ** លោក លោកស្រី អនុប្រធាន និងជាសមាជិក ដែលជា ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត៕











# បន្ទាប់ពីវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តការងារ ផ្នែកថែទាំសុខភាព រយៈពេល ១ថ្ងៃកន្លងមក ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. តាមបណ្តាសាខា រាជធានី-ខេត្ត ទទួលបានបទពិសោធន៍កាន់តែច្រើនក្នុងការបំពេញកិច្ចការរបស់ខ្លួន

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម បានអញ្ជើញជាធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីអនុវត្តការងារ ផ្នែកថែទាំសុខភាព ដល់ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. តាមបណ្តាសាខាទូទាំងរាជធានី-/ខេត្ត សរុបប្រមាណជាង ៨០នាក់ នាថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ នេះ នៅសាលប្រជុំធំនៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ។

**ឯកឧត្តម** បានថ្លែងដោយក្តីជឿជាក់ថា៖ លោកលោកស្រីទាំងអស់នឹងយកបទពិសោធន៍ថ្មីៗ ទាក់ទងទៅនឹងការងារសម្របសម្រួលសេវាមូលដ្ឋានសុខាភិបាល បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវា របៀបបញ្ចូលទិន្នន័យក្នុងប្រព័ន្ធភាពខុសគ្នារវាងតាវកាលិក កម្មករនិយោជិត និងមន្ត្រីរាជការ យន្តការទូទាត់ថ្លៃសេវារបស់កម្មករនិយោជិត និងមន្ត្រីរាជការ នីតិវិធិនៃការចុះបញ្ជិកា និងបង់ភាគទានរបស់កម្មករនិយោជិតក្នុង និងក្រៅប្រព័ន្ធ តាវកាលិកសម្រាប់ផ្នែកថែទាំសុខភាព និងអភិបាលកិច្ច អង្កេតគ្រោះថ្នាក់ការងារ ច្បាប់ការងារ និងអធិការកិច្ចទៅអនុវត្តឱ្យបានត្រឹមត្រូវ។





**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានជម្រុញបន្ថែមឱ្យលោក លោកស្រី ដែលជា ប្រធាន អនុប្រធាន និងមន្ត្រី-ប.ស.ស. តាមបណ្តាសាខារាជធានី-ខេត្ត ទាំងអស់ពន្លឿនក្នុងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនិងប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីសម្រាលកូនឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តម** បានបន្តទៀតថា ក្នុងនាមយើងជាមន្ត្រីរាជការត្រូវធ្វើយ៉ាងណាបម្រើសេវាជូនបងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិតឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនិងគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធិភាពខ្ពស់៕












# ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ អ្នកស្លាប់ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ មានចំនួន ៤៨៨នាក់ ក្នុងនោះកម្មករនិយោជិតមានរហូតដល់ទៅ ៣៨% នៃអ្នកដែលបានគ្រោះថ្នាក់ស្លាប់សរុប

នេះជាការលើកឡើងពីសំណាក់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ឹម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានអចិន្ត្រៃយ៍អនុគណៈកម្មាការទី២ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់មួយស្តីពីការជម្រុញការកែលម្អសុវត្ថិភាព-រថយន្តដឹកកម្មករនិយោជិត នាថ្ងៃអង្គារ ៩កើត ខែកត្តិក ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

ជាមួយគ្នានេះដែរ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខ-សង្គម ប.ស.ស. និងជាប្រធានក្រុមការ-ងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃប.ស.ស. បានថ្លែងបញ្ជាក់ថា៖ការគិតគូរពីសុវត្ថិភាពធ្វើដំណើររបស់បងប្អូនដែលជាកម្មករនិ-យោជិត ជាកត្តាដ៏សំខាន់ដែលគ្រប់អង្គ-ភាពពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ហើយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកគឺជាឃាតករលាក់មុខដែលធ្វើឱ្យមនុស្សស្លាប់របួស និងពិការជារៀងរាល់ថ្ងៃ។ បញ្ហា-ប្រឈមដ៏ធ្ងន់ធ្ងរនេះ មិនអាចឱ្យក្រសួងស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់កាត់បន្ថយ ឬលុបបំបាត់តែឯងបានឡើយ ប៉ុន្តែយើងអាចសហការគ្នាទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យស្ថិតនៅកម្រិតទាបបំផុត។





**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ដើម្បីដោះស្រាយចំពោះស្ថានភាពនេះកន្លងមកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក នៃបេឡាជាតិសន្តិសុខសង្គម ដែលមានសមាសភាពជាក្រុមការងារអន្តរក្រសួង ក្នុងនោះមានដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសាធារណការនិងដឹកជញ្ជូន សាលារាជធានីភ្នំពេញ កាកបាទក្រហមកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីព តំណាងកម្មករនិយោជិត អង្គការជនពិការអន្តរជាតិ និងអង្គការមូលនិធិបង្ការរបួសអាស៊ី ដែលមានតួនាទីសំខាន់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត។

ជាមួយគ្នានេះដែរ **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលរំពឹងថា៖ឆ្លងកាត់សិក្ខាសាលានេះនឹងទទួលបានលទ្ធផលល្អប្រសើរប្រកបដោយផ្លែផ្កា ក្នុងការចូលរួមអនុវត្តផែនការសកម្មភាព "សុវត្ថិភាពចរាចរណ៍ផ្លូវគោក ចំពោះកម្មករនិយោជិត" ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បេឡាជាតិសន្តិសុខសង្គម និងអគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបង្កើននូវកិច្ចសហការក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរគ្រប់រូបភាព ក្នុងន័យចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដែលធ្លាក់មកលើកម្មករនិយោជិត ឱ្យស្ថិតនៅកម្រិតទាបបំផុត។ មួយវិញទៀតក្នុងការលើកកម្ពស់សុវត្ថិភាព ផាសុខភាព និងសណ្តាប់ធ្នាប់ ដល់បងប្អូនកម្មករនិយោជិត ដែលបានធ្វើដំណើរតាមរថយន្តដែលអាចឆ្លើយតបទៅនឹងបញ្ហាដែលកំពុងប្រឈមគប្បីកែលម្អរថយន្តដឹកកម្មករនិយោជិតឱ្យមានភាពល្អប្រសើរ និងកាន់តែមានប្រសិទ្ធភាពស្របទៅតាមច្បាប់បានកំណត់។

សូមបញ្ជាក់ថា៖ សិក្ខាសាលាពិគ្រោះយោបល់ខាងលើប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម ប.ស.ស. ដោយមានវត្តមាន **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ឹម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ ជាអនុប្រធានអចិន្ត្រៃយ៍អនុគណៈកម្មាការទី២ និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន មន្ទីរសាធារណការដឹកជញ្ជូន ស្នងការដ្ឋាននគរបាល សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) តំណាងសហព័ន្ធសហជីពកម្ពុជា តំណាងតំបន់សេដ្ឋកិច្ចពិសេស តំណាងរោងចក្រ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា សរុបប្រមាណជាង ៣៥០នាក់ នៅ Dara Airport Hotel & Spa រាជធានីភ្នំពេញ ៕







# ពិធីទទួលទានអំបុក
## ដើម្បីចូលរួមការពារជាតិ សាសនា និងព្រះមហាក្សត្រ របស់យើង

ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកស្ថាប័នបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរាជធានីភ្នំពេញ នៅថ្ងៃ៩ វិច្ឆិកា ឆ្នាំ២០១៩ នេះ បានជួបជុំគ្នាទទួលទានអំបុកប្រកបដោយបរិយាកាសសាមគ្គីភាពស្និទ្ធស្នាល និងសប្បាយរីករាយ។

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម បានថ្លែងថា៖ ការជួបជុំគ្នាទទួលទានអំបុកសម្រាប់ថ្ងៃទី៩ វិច្ឆិកានេះ ត្រូវបានប្រកាសឡើងដោយ **សម្តេចតេជោ ហ៊ុន សែន** ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ក្នុងន័យហូបអំបុកខ្មែរថៃជាតិ សាសនា ព្រះមហាក្សត្រ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តថា៖ ព្រឹត្តិការណ៍ហូបអំបុក នៅថ្ងៃទី៩ ខែវិច្ឆិកានេះក្នុងន័យជួយដាស់តឿនដល់កូនខ្មែរសម័យទំនើប ឱ្យស្គាល់កាន់តែច្បាស់នូវអ្វីដែលជាអត្តសញ្ញាណជាតិខ្មែរ ប្រពៃណីអកអំបុកនេះ ដូនតាខ្មែរយើងបានប្រារព្ធឡើងយ៉ាងជាប់លាប់តាំងតែពីបុរាណកាលរៀងមក គឺការធ្វើឡើងនៅក្រោយពេលរដូវប្រមូលផលស្រូវរួច។







បន្ទាប់ពីបង្អកអំបុកហើយគេបង្អកចេកថែមទៀត ឯបុរសក៏អាចយកអំបុកអកទៅលើស្ត្រីវិញផងដែរ ក្នុងបរិយាកាស យ៉ាងសប្បាយរីករាយ ទៅតាមទំនៀមទម្លាប់ប្រពៃណីជាតិ។ ប្រពៃណីអកអំបុកនេះ ក៏បានបង្ហាញពីសាមគ្គីភាព ដ៏ស្និទ្ធស្នាល និងភាពសំបូរហូរហៀរនៅក្នុងសង្គមសុខសន្តិភាព។

សូមបញ្ជាក់ថា៖ នៅក្នុងពិធីប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីថ្ងៃទី ៧ វិច្ឆិកាកន្លងមកនេះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទូទាំងប្រទេស ព្រមទាំងបងប្អូនដែលកំពុងពួនលាក់ខ្លួននៅភ្នំក្រវ៉ាញ និងនៅតាមកន្លែងដទៃៗទៀត សូមចេញមករសារភាព កុំមានការភ័យខ្លាច ចូលរួមសប្បាយរីករាយជាមួយក្រុមគ្រួសារនៅក្នុងថ្ងៃបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា នេះ និងនៅក្នុងព្រះរាជពិធីបុណ្យអុំទូក អកអំបុក លយប្រទីប និងសំពះព្រះខែ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១០-១២ ខែវិច្ឆិកា ឆ្នាំ ២០១៩នេះ៕










# បេឡាជាតិសន្តិសុខសង្គម គ្រោងនឹងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធននៅពេលឆាប់ៗខាងមុខនេះ

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នាថ្ងៃសុក្រ ៤រោច ខែកត្តិក ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ-២០១៩ នៅក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការដាក់ឱ្យដំណើរការ "របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ" បានឱ្យដឹងថា៖ ការបង្កើតឱ្យមានរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធននេះឡើង គឺដើម្បីការពារហិរញ្ញវត្ថុពលរដ្ឋពេលចាស់ជរាតាមយៈការផ្តល់ប្រាក់ចំណូលសមរម្យចំពោះប្រជាជនដែលបានចូលរួមក្នុងរបបប្រាក់សោធនដោយបញ្ឈប់នូវទម្លាប់ចិញ្ចឹមគ្នាទៅវិញទៅមកដែលធ្វើឱ្យបន្ទុកចំណាយក្នុងគ្រួសារកាន់តែមានការកើនឡើងជាហេតុធ្វើឱ្យជីវភាពគ្រួសារនៃប្រជាជនកម្ពុជាកាន់តែធ្លាក់ចុះ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តថា៖ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ គោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ក្នុងនោះ គោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម នៅកម្ពុជាក៏ត្រូវបានយកចិត្តទុកដាក់ និងជម្រុញឱ្យមានការកែលម្អកាន់តែមានប្រសិទ្ធភាព







និងស័ក្តិសិទ្ធភាព សំដៅដល់ការជម្រុញការការពារសុខុមាលភាពជីវភាពរស់នៅរបស់ប្រជាជនជា ពិសេសបងប្អូនកម្មករនិយោជិត។

**ឯកឧត្តម** ប្រតិភូបានបន្តទៀតថា៖ ដើម្បីឱ្យរបបសន្តិសុខសង្គមដ៏ល្អមួយនេះ អាចគ្របដណ្តប់បានទូលំទូលាយរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឱ្យមានច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ដែលរួមមាន១១ជំពូក និង១០៧មាត្រា ដោយបានប្បញ្ញត្តិអំពីតួនាទីភារកិច្ចច្បាស់លាស់របស់និយ័តករសន្តិសុខសង្គម ប្រតិបត្តិករសន្តិសុខសង្គម ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. និងក្រុមប្រឹក្សាធនាភិបាលដែលជាអង្គភាពវិនិយោគមូលនិធិសន្តិសុខសង្គមនៅកម្ពុជា។ ជាពិសេសគោលការណ៍ទូទៅ នៃរបបសន្តិសុខសង្គមដែលរួមមានរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ។ កន្លងមកបេឡាជាតិសន្តិសុខសង្គម បានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងថែទាំសុខភាពរួចមកហើយរបបទាំងពីរនេះក៏បានជួយសម្រាលបន្ទុកយ៉ាងច្រើនដល់ និយោជិតនៃវិស័យឯកជន ក៏ដូចជាមន្ត្រីរាជការនៅពេលជួបប្រទះហានិភ័យផ្សេងៗ កើតឡើងជាយថាហេតុកន្លងមក។ ដោយសារការខិតខំប្រឹងប្រែងរបស់មន្ត្រី និងបុគ្គលិកនៃ ប.ស.ស. កន្លងមក និងដោយសារមានការទុកចិត្តពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ប.ស.ស. គ្រោងនឹងដាក់ឱ្យដំណើរការ ″ ប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ″ នៅកម្ពុជា នាដើមឆ្នាំ២០២០ ឆាប់ៗខាងមុខនេះ ដើម្បីជួយសម្រាលបន្ទុកដល់ បងប្អូនប្រជាពលរដ្ឋពិសេសបងប្អូនកម្មករនិយោជិត នៅពេលចាស់ជរា និងខ្វះលទ្ធភាពស្វែងរកប្រាក់ចំណូល។








គួររំលឹកផងដែរថា៖ បើយោងតាមរបាយការណ៍នៃការសិក្សាស្រាវជ្រាវមួយរបស់អង្គការអន្តរជាតិខាងការងារ (ILO) បានចង្អុលបង្ហាញថា បច្ចុប្បន្នមានប្រជាជនកម្ពុជាប្រមាណ ៦,៥ ភាគរយ ដែលមានអាយុលើសពី ៦០ឆ្នាំ។ ដោយទិន្នន័យក្នុងពេលបច្ចុប្បន្ននេះ ក្រុមប្រជាជនដែលមានអាយុចាប់ពី ០ ដល់ ១៤ ឆ្នាំ មានចំនួន ៥លាននាក់ ក្រុមប្រជាជនដែលមានអាយុចាប់ពី ១៥ ដល់ ៥៤ឆ្នាំ មានចំនួនប្រមាណជាង ៩លាននាក់ និងក្រុមប្រជាជនដែលមានអាយុចាប់ពី ៥៥ឆ្នាំ ឡើងទៅមានចំនួនប្រមាណជាង ១លាននាក់ ដែលសមាមាត្រនេះ ត្រូវបានរំពឹងថា នឹងមានការកើនឡើងប្រមាណ ២៤% (ភាគរយ) ប្រហែលជាង ៧លាន នាក់ នាឆ្នាំ២០៦៨ ក្នុងរយៈពេល ៥០ឆ្នាំខាងមុខ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបញ្ជាក់ទៀត-ថា៖ ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជានេះគឺជាពេលវេលាដ៏ស័ក្តិសមបំផុតក្នុងការបង្កើតឱ្យមានរបបសន្តិសុខ-សង្គម ផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជននៅកម្ពុជា ដើម្បីទប់ស្កាត់នូវបញ្ហាប្រឈមដោយសារអត្រាមនុស្សចាស់កើនឡើងក្នុងរយៈពេល ៥០ឆ្នាំខាងមុខ ហើយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះក៏នឹងជួយទំនុកបម្រុងជីវភាពប្រជាជនពេលចាស់ជរាខ្វះលទ្ធភាពស្វែងរកប្រាក់ចំណូល ព្រមទាំងកាត់បន្ថយបន្ទុកចំណាយក្នុងគ្រួសារ និងទម្លាប់ចិញ្ចឹមតគ្នា (ឪពុកម្តាយមានកាតព្វកិច្ចចិញ្ចឹមកូនវិញកូនមានករណីកិច្ចចិញ្ចឹមឪពុកម្តាយវិញពេលចាស់ជរា) ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល សង្ឃឹមជឿជាក់យ៉ាងមុតមាំថា បន្ទាប់ពីបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់នេះ សិក្ខាកាមទាំងអស់នឹងចូលរួមចំណែកយ៉ាងសកម្ម ដើម្បីផ្តល់ជាធាតុចូលសំខាន់ៗជាច្រើនបន្ថែមទៀត ឱ្យការអនុវត្តរបបប្រាក់សោធនសម្រាប់វិស័យឯកជននៅកម្ពុជាកាន់តែមានលក្ខណៈល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមបញ្ជាក់ថា៖ សិក្ខាសាលាពិគ្រោះយោបល់ខាងលើប្រព្រឹត្តទៅនៅ Dara Airport Hotel & Spa រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជ-រដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានវត្តមានចូលរួមពី តំណាងសហព័ន្ធនិយោជក សមាគមពា-ណិជ្ជកម្មកម្ពុជា អង្គការដៃគូអភិវឌ្ឍ និងស្ថាប័ន-អង្គភាពពាក់ព័ន្ធសរុបប្រមាណជាង ១០០នាក់៕







# ឯកឧត្តម ស៊ុំ សោភ័ណ អញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការអភិវឌ្ឍកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ាន ឆ្នាំ២០២១-២០២៥

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) តំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមក្នុងវគ្គសិក្ខាសាលា ស្តីពីការអភិវឌ្ឍកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ាន ឆ្នាំ២០២១-២០២៥ ក្រោមការរៀបចំដោយក្រសួងការងារជនពិការ និងសង្គមកិច្ច នៅទីក្រុងហាឡុងនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

សិក្ខាសាលានេះ ផ្តោតសំខាន់លើការពិភាក្សារវាងប្រទេសសមាជិកអាស៊ាន និងអាស៊ាន+៣ លើវិស័យ និងគម្រោងសកម្មភាពគោលសំខាន់ៗ ដែលនឹងត្រូវដាក់បញ្ចូលក្នុងកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ាន (ALM-WP) ផែនការងាររបស់ SLOM-WG និងផែនការការងាររបស់ SLOM+៣ ឆ្នាំ២០២១-២០២៥។

សិក្ខាសាលាស្តីពីការអភិវឌ្ឍកម្មវិធីការងាររបស់រដ្ឋមន្ត្រីការងារអាស៊ាន ឆ្នាំ២០២១-២០២៥ នេះ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៦-១៧ ខែតុលា ឆ្នាំ២០១៩ ដោយមានអ្នកចូលរួមមកពីតំណាងក្រសួងការងារ នៃប្រទេសជាសមាជិកអាស៊ាន និងអាស៊ាន+៣ (ប្រទេសជប៉ុន ចិន និងប្រទេសកូរ៉េខាងត្បូង) សរុបប្រមាណ ៧០នាក់៕









# ម្ចាស់សហគ្រាស គ្រឹះស្ថាន និងតំណាងសហគ្រាសថ្មី ចូលរួមស្វែងយល់ពីការចុះបញ្ជិកាសហគ្រាស ការបង់ភាគទាន និងការប្រើប្រាស់ទម្រង់ E-Form ថ្មី

នៅថ្ងៃសុក្រ ៥កើត ខែកក្ដិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆកា ឆ្នាំ២០១៩ បេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការចុះបញ្ជិកាសហគ្រាស ការបង់ភាគទាន និងការប្រើប្រាស់ទម្រង់ E-Form ថ្មី ព្រមទាំងប្រគល់វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ដែលទើបចុះបញ្ជិកា មកក្នុង ប.ស.ស. ក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន នរៈឧុធ** នាយករង ប.ស.ស. ដែលមានការចូលរួមពីម្ចាស់សហគ្រាស តំណាង សហគ្រាស គ្រឹះស្ថានថ្មី សរុបចំនួន ៦៤ សហគ្រាស នៅសាលប្រជុំធំស្នាក់ការកណ្តាល នៃ ប.ស.ស. រាជធានីភ្នំពេញ។

ការប្រជុំនេះ **ឯកឧត្តម** នាយករង បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា និងបង់ភាគទានមក ប.ស.ស. ដើម្បីធានានូវសុខភាព សុវត្ថិភាពការងារ និងធានានូវសន្តិសុខប្រាក់ចំណូលរបស់កម្មករនិយោជិតទាំងអស់។

នៅទីបញ្ចប់ **ឯកឧត្តម** នាយករង បានសំណូមពរដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន សូមមកចុះបញ្ជិកាសហគ្រាស និងកម្មករនិយោជិត មកក្នុង ប.ស.ស. ព្រមទាំងផ្តល់របាយការណ៍កម្មករនិយោជិត ឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានអត្ថប្រយោជន៍ផ្សេងៗ ពី ប.ស.ស.៕










# នៅពេលឆាប់ៗខាងមុខនេះ បេឡាជាតិសន្តិសុខសង្គម នឹងដាក់ឱ្យអនុវត្តជាផ្លូវការនូវរបបសន្តិសុខសង្គមថ្មីផ្នែកប្រាក់សោធន




ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះឡើង គឺដើម្បីការពារហិរញ្ញវត្ថុពលរដ្ឋពេលចាស់ជរាតាមរយៈការផ្តល់ប្រាក់ចំណូលសមរម្យចំពោះប្រជាជនដែលបានចូលរួមក្នុងរបបប្រាក់សោធន ដោយបញ្ឈប់នូវទម្លាប់ចិញ្ចឹមគ្នាទៅវិញទៅមក ដែលធ្វើឱ្យបន្ទុកចំណាយក្នុងគ្រួសារកាន់តែមានការកើនឡើង។

ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីនេះ រួមមាន ១១ជំពូក និង ១០៧មាត្រា ដែលបានប្បញ្ញត្តិអំពីតួនាទីភារកិច្ចច្បាស់លាស់របស់និយ័តករសន្តិសុខសង្គម ប្រតិបត្តិករសន្តិសុខសង្គម ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. និងក្រុមប្រឹក្សាធនាភិបាលដែលជាអង្គភាពវិនិយោគមូលនិធិសន្តិសុខសង្គមនៅកម្ពុជា និងជាពិសេសគោលការណ៍ទូទៅ នៃរបបសន្តិសុខសង្គមដោយរួមមាន របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ ។





**ឯកឧត្តម ប៉ែន នរៈឧុធ** នាយករង ប.ស.ស. សង្ឃឹមជឿជាក់យ៉ាងមុតមាំថា បន្ទាប់ពីបញ្ចប់សិក្ខាសាលាពិគ្រោះ-យោបល់ នឹងរួមចំណែកយ៉ាងសកម្ម ដើម្បីផ្តល់ជាធាតុចូលសំខាន់ៗជាច្រើនបន្ថែមទៀតក្នុងការអនុវត្តរបបប្រាក់សោធនសម្រាប់វិស័យឯកជន នៅកម្ពុជាកាន់តែមានលក្ខណៈល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមបញ្ជាក់ថា៖ សិក្ខាសាលាពិគ្រោះយោបល់ខាងលើប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន នរៈឧុធ** នាយក-រងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) តំណាងដ៏ខ្ពង់ខ្ពស់



**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. នាថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯក-ស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅ Dara Airport Hotel & Spa រាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីសហព័ន្ធនិយោជក សហព័ន្ធសហជីពកម្ពុជា អង្គការដៃគូអភិវឌ្ឍ និងស្ថាប័ន អង្គភាពពាក់ព័ន្ធនានា សរុបប្រមាណជា ៨០នាក់៕









# ក្រុមអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជួបពិភាក្សាការងារជាមួយមន្ត្រីជំនាញ បេឡាជាតិសន្តិសុខសង្គម លើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា សម្រាប់កម្មវិធីគាំពារសង្គម

ក្រោមការចាត់តាំង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក (ប.ស.ស.) **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) រួមទាំងសហការី បានជួបពិភាក្សាជាមួយក្រុមអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នាថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ នៅសាលប្រជុំនៃទីស្នាក់ការកណ្តាល ប.ស.ស. នៅរាជធានីភ្នំពេញ។

ក្នុងជំនួបពិភាក្សាខាងលើ មានគោលបំណងផ្តោតសំខាន់ទៅលើការប្រមូល និងវិភាគលើទិន្នន័យ ដែលមានស្រាប់ ដើម្បីមានមូលដ្ឋានក្នុងការរៀបចំឯកសារទស្សនាទានស្តីពីការអនុវត្តលើការធ្វើសុខដុមនីយកម្មប្រព័ន្ធគាំពារសង្គម ជាមួយនឹងប្រព័ន្ធអត្តសញ្ញាណកម្មជាតិ។

បច្ចុប្បន្ន បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បាននឹងកំពុងប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់កម្មវិធីគាំពារសង្គមរបស់ខ្លួន ដែលជាប្រព័ន្ធមួយជួយសម្រួលក្នុងការងារផ្តល់សេវា គ្រប់គ្រងទិន្នន័យ និងប្រមូលទិន្នន័យ ដែលមានរួចមកហើយ និងកំពុងបន្តរហូតមកដល់ពេលនេះ។ ដោយឡែក នៅថ្ងៃខាងមុខ ប.ស.ស. អាចនឹងធ្វើការពង្រីកនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់កម្មវិធីគាំពារសង្គមរបស់ខ្លួនឱ្យកាន់តែទូលំទូលាយបន្ថែមទៀត៕







# មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម (កម្ពុជា) ០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីហិរញ្ញវត្ថុសាធារណៈសម្រាប់ការវិភាគប្រព័ន្ធកិច្ចគាំពារសង្គម

Public Finance for Social Protection Analysts

A9012022 • Turin (Italy), 7 – 18 October 2019

មន្ត្រីជំនាញរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ០១រូប ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក (ប.ស.ស.) ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីហិរញ្ញវត្ថុសាធារណៈសម្រាប់ការវិភាគប្រព័ន្ធកិច្ចគាំពារសង្គម (Training Course on Public Finance for Social Protection Analysts) ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិ នៃអង្គការអន្តរជាតិខាងការងារ (ITC/ILO) ក្រោមការឧបត្ថម្ភគាំទ្រដោយ(GIZ)។ វគ្គបណ្តុះបណ្តានេះមានគោលបំណងផ្តល់ជំនាញអនុវត្តន៍ដល់សិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកិច្ចគាំពារសង្គម ដើម្បីវាយតម្លៃជម្រើសហិរញ្ញប្បទានសម្រាប់កិច្ចគាំពារសង្គម និងអភិវឌ្ឍផែនការហិរញ្ញប្បទានដែលគ្រោងឡើងសម្រាប់ប្រទេសនីមួយៗ លក្ខណៈសំខាន់ នៃវគ្គបណ្តុះបណ្តាលនេះគឺជាការរួមបញ្ចូលគ្នាសម្រាប់វិស័យហិរញ្ញវត្ថុសាធារណៈនិងវិស័យកិច្ចគាំពារសង្គម។










តាមរយៈវគ្គបណ្តុះបណ្តាលនេះដែរ ក៏បានផ្តល់នូវចំណេះដឹងជាមូលដ្ឋាន ផ្នែកហិរញ្ញវត្ថុសាធារណៈ ក្នុងនោះរួមមាន ការប្រមូលចំណូលប្រចាំឆ្នាំ និងការអភិវឌ្ឍថវិកា និងការកសាងចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ការវិភាគផ្នែកហិរញ្ញប្បទានកិច្ចគាំពារសង្គម។ វាក៏បានរួមបញ្ចូលរបកគំហើញមួយចំនួន នៃហិរញ្ញប្បទានប្រព័ន្ធកិច្ចគាំពារសង្គមផងដែរ តាមរយៈភាគទានរបស់កម្មករនិយោជិត និងនិយោជកជាដើម ។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើ ប្រព្រឹត្តទៅចំនួន ១២ថ្ងៃ គឺចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ស្ថិតនៅទីក្រុងទូរីន ប្រទេសអ៊ីតាលី ដោយមានវត្តមានចូលរួមពី តំណាងអង្គភាព/ស្ថាប័ន នៃរដ្ឋាភិបាល ដៃគូរសង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចនៃស្ថាប័នសន្តិសុខសង្គម ទីភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់កិច្ចគាំពារសង្គម តំណាងមកពីអង្គការក្រៅរដ្ឋាភិបាល និងវិទ្យាស្ថានស្រាវជ្រាវដែលពាក់ព័ន្ធនឹងកិច្ចគាំពារសង្គមជាច្រើនផងដែរ៕








# មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញនៃកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ

ក្រោមការចាត់តាំងពី **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញនៃកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ (The Art of Stakeholder Collaboration) ដែលរៀបចំឡើងដោយវិទ្យាស្ថានប្រមូលផ្តុំភាពជាអ្នកដឹកនាំ (Collective Leadership Institute) នៃប្រទេសអាល្លឺម៉ង់ ក្រោមការឧបត្ថម្ភគាំទ្រដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)។





**ឯកឧត្តម ហេង សុផាន់ណារិទ្ធ** បានឱ្យដឹងថា៖ វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់ទៅលើការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមដែលស្មុគស្មាញសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសគឺការកសាងសមត្ថភាពជាយុទ្ធសាស្រ្ត ការអនុវត្តជំនាញក្នុងការទំនាក់ទំនង កិច្ចសន្ទនា និងដំណើរការនៃកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ។

គួរបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើនេះ ប្រព្រឹត្តទៅចំនួន៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៦-១៩ ខែតុលា ឆ្នាំ២០១៩ ស្ថិតនៅខេត្តសៀមរាប ដោយមានអ្នកចូលរួមប្រមាណ ៤០រូប មកពីបណ្តាប្រទេសចំនួន៥ រួមមាន កម្ពុជា ឡាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប្រទេសបង់ក្លាដេស៕



# មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម កម្ពុជា ៤រូប ចូលរួមវគ្គបណ្តុះបណ្តាល ថ្នាក់តំបន់ស្តីពីការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម

មន្ត្រីជំនាញបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា ៤រូប ត្រូវបានចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. ទៅចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម (Regional Training on Actuarial Analysis of Social Health Insurance Fund) នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

គោលបំណងសំខាន់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលខាងលើ គឺដើម្បីទទួលបានការបណ្តុះបណ្តាលបន្ថែមអំពីជំនាញការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គមដែលបណ្តាប្រទេសជិតខាង និងប្រទេសកំពុងអភិវឌ្ឍន៍នានាបាននឹងកំពុងមានការគិតគូរយ៉ាងខ្លាំង ដោយសារវាជាផ្នែកមួយដ៏សំខាន់នៃរបបសន្តិសុខសង្គម ដែលជាវិស័យមួយកំពុងទទួលបានការយកចិត្តទុកដាក់អំពីរាជរដ្ឋាភិបាលនៅក្នុងគោលនយោបាយនានា ក៏ដូចជាមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណអាណត្តិទី៤ផងដែរនៅក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាពសង្គម។ ការបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលខាងលើគឺជាការឆ្លើយតបទៅនឹងតម្រូវការនៃការបង្កើនសមត្ថភាពរបស់អ្នកជំនាញបច្ចេកទេសថ្នាក់ជាតិទាក់ទងទៅនឹងជំនាញ ស្តីពីការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម ក៏ដូចជាការប្រើប្រាស់ចំណេះដឹងមួយនេះ សម្រាប់ការងាររដ្ឋបាលនានា ក៏ដូចជាការផ្តល់ជាអនុសាសន៍នៅក្នុងការកសាងគោលនយោបាយពាក់ព័ន្ធនានា ដែលសកម្មភាពចម្បងៗរួមមានដូចខាងក្រោម៖

- បង្កើនការចាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធទៅលើសារសំខាន់នៃការបង្កើតការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម ដើម្បីទទួលបានការត្រួតពិនិត្យទៅលើស្ថានភាពហិរញ្ញវត្ថុនៃគោលនយោបាយធានារ៉ាប់រងសុខភាព។

- ធ្វើការផ្តល់ការយល់ដឹងអំពីទស្សនៈមូលដ្ឋាន គោលការណ៍ និងធាតុសំខាន់នានានៃការប៉ាន់ស្មានការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម។
- ផ្តល់ការណែនាំទៅដល់ផ្នែកធានារ៉ាប់រងសុខភាពនៅក្នុងការរក្សា និងស្វែងរកទិន្នន័យសម្រាប់ធ្វើការគ្រប់គ្រង ដើម្បីធ្វើការប៉ាន់ស្មានការទូរទាត់ការធានារ៉ាប់រងហានិភ័យការងារ និងបង្កើតជាអនុសាសន៍នានាសម្រាប់បង្កើតនូវគុណភាពទិន្នន័យទទួលបាន។
- សម្របសម្រួលការយល់ដឹងអំពីការពិនិត្យឡើងវិញនៃការប៉ាន់ស្មានការវិភាគហានិភ័យហិរញ្ញវត្ថុផ្នែកមូលនិធិធានារ៉ាប់រងសុខភាពសង្គម អំពីសំណាក់អាជ្ញាធរជាតិ និងធ្វើការបកស្រាយចំណុចនានានៃការប៉ាន់ស្មានការទូរទាត់ការធានារ៉ាប់រងហានិភ័យការងារប្រកបដោយសក្តីកម្មជាក់លាក់នៅក្នុងការអភិវឌ្ឍគោលនយោបាយរដ្ឋបាលនានា។
- ជម្រុញឱ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍ និងការអនុវត្តនានាក្នុងចំណោមប្រទេសចូលរួមទាំងអស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើ ប្រព្រឹត្តចំនួន៥ថ្ងៃ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ មានការរៀបចំដោយអង្គការអន្តរជាតិខាងការងារ (ILO) ក្រោមការឧបត្ថម្ភគាំទ្រដោយអង្គការអន្តរជាតិស្តីពីការងារ (ILO) និងអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដែលមានសិក្ខាកាមចូលរួមមកពី៥ ប្រទេសរួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងប្រទេសវៀតណាមជាម្ចាស់ផ្ទះ៕









# មន្ត្រី ប.ស.ស. កម្ពុជាចំនួន ២រូប ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី "អភិបាលកិច្ចល្អ លើការវិនិយោគប្រកបដោយចីរភាព និងនិរន្តរភាពការអភិវឌ្ឍន៍សង្គម និងបរិស្ថាន"

មន្ត្រីជំនាញ ២រូប នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម បានចូលរួមកិច្ចប្រជុំពិភាក្សា ASEAN Pension Funds and Social Security System Summit (APIC) លើប្រធានបទ "អភិបាលកិច្ចល្អលើការវិនិយោគប្រកបដោយចីរភាព និងនិរន្តរភាពការអភិវឌ្ឍន៍សង្គម និងបរិស្ថាន" នៅ Mandarin Oriental Hotel ក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

**លោក គាត ពុធណារិទ្ធិ** ប្រធានការិយាល័យសោធន តំណាងឱ្យបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជាបាន ឱ្យដឹងថា៖ គោលបំណង នៃកិច្ចប្រជុំពិភាក្សាខាងលើ គឺផ្តោតសំខាន់ទៅលើការវិនិយោគមូលនិធិសោធន Environmental Social and - Governance (ESG) និង Sustainable Development Goal (SDG) ដើម្បីការពារផលប្រយោជន៍របស់និយោជិត។

លោកបានឱ្យដឹងបន្ថែមថា៖ ក្នុងកិច្ចប្រជុំពិភាក្សានេះ តំណាងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) កម្ពុជា ត្រូវបានអង្គប្រជុំអនុញ្ញាតឱ្យបង្ហាញអំពីវឌ្ឍនៈភាព នៃការអនុវត្តរបបសន្តិសុខសង្គមរបស់កម្ពុជា ក៏ដូចជាបទពិសោធន៍កន្លងមកដែលកម្ពុជាអនុវត្តលើវិស័យដ៏ល្អមួយនេះ បានជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ទៅកាន់សិក្ខាកាម នៃបណ្តាប្រទេសជាច្រើនដែលបាន-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាខាងលើ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅចំនួន ២ថ្ងៃ គឺចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដោយមានសិក្ខាកាមចូលរួមមកពីបណ្តាប្រទេសចំនួន ១២ រួមមាន៖ កម្ពុជា ម៉ាឡេស៊ី មីយ៉ាន់ម៉ា អូស្ត្រាលី សាំងហ្គាពួ ជប៉ុន អង់គ្លេស កូរ៉េ ចិន កាណាដា ហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី សរុបប្រមាណជាង ៤០ រូប៕








# មន្ត្រី បេឡាជាតិសន្តិសុខសង្គម កម្ពុជាចំនួន ១៣រូប ទៅបំពេញទស្សនៈកិច្ចសិក្សាស្តីពី " ប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គម "

ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) មន្ត្រីរបស់ខ្លួនចំនួន ១៣រូបទៅបំពេញទស្សនៈកិច្ចសិក្សាស្តីពី " ប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គម " នៅប្រទេសហ្វីលីពីន ។

តាមការបញ្ជាក់ **លោក ស្រិល ស៊ីថាត** តំណាង ប.ស.ស. កម្ពុជា បានឱ្យដឹងថា៖ ការទៅចូលរួមដំណើរទស្សនៈកិច្ចសិក្សាខាលើ មានគោលបំណងដើម្បីស្វែងយល់ពីចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- សិក្សាអំពីប្រតិបត្តិការ និងការអនុវត្តនៃប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមរបស់អង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន (PhilHealth)
- ស្វែងយល់អំពីទំនាក់ទំនងរវាងស្នាក់ការកណ្តាល (H-Q) និងការិយាល័យសាខាថ្នាក់តំបន់/ខេត្តរបស់អង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន(PhilHealth)
- ស្វែងយល់អំពីការធ្វើប្រតិភូកម្មនៃតួនាទីនិងភារកិច្ចរបស់ស្នាក់ការកណ្តាល (H-Q) និងការិយាល័យសាខាថ្នាក់តំបន់/ខេត្តរបស់អង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន (PhilHealth) ។

លោកបានបញ្ជាក់បន្ថែមទៀតថា៖ ដំណើរទស្សនៈកិច្ចសិក្សាមួយនេះ គឺផ្តល់សារៈសំខាន់ ខ្លាំងណាស់ក្នុងការផ្លាស់ប្តូរបទពិសោធន៍ការងារ និងស្វែងយល់នូវចំណេះដឹងបន្ថែមទៀត ស្តីពីការអនុវត្តវិស័យសន្តិសុខសង្គមពិភពលោក ដើម្បីយកមកអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និងភាពល្អប្រសើរ នៃការរៀបចំឱ្យមានកិច្ចសហការរវាងរបបសន្តិសុខសង្គមកម្ពុជា និងវិស័យសន្តិសុខសង្គមនៃបណ្តាប្រទេសនានាទូទាំងពិភពលោក។



សូមបញ្ជាក់ថា៖ ដំណើរទស្សនៈកិច្ចសិក្សាស្វែងយល់ខាងលើនេះ ប្រព្រឹត្តទៅចំនួន ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមានការចូលរួមពីមន្ត្រីជំនាញ តំណាងឱ្យ ប.ស.ស. កម្ពុជា ១៣រូប និងតំណាងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ប្រចាំកម្ពុជាជាច្រើននាក់ ៕



# ក្រុមអាហារទាំង៣ពណ៌នេះ សំខាន់យ៉ាងណាខ្លះចំពោះរាងកាយយើង?

អាហារដែលយើងញ៉ាំជារៀងរាល់ថ្ងៃ មាន៣ក្រុមធំៗ គឺក្រុមអាហារពណ៌លឿង ពណ៌ក្រហម និងពណ៌បៃតង។ ខាងក្រោមនេះជាអត្ថប្រយោជន៍របស់អាហារទាំង៣ក្រុមនេះចំពោះរាងកាយយើងដែលបានចងក្រងនៅក្នុងសៀវភៅសំណួរ–ចម្លើយរៀបរៀងដោយមន្ទីរពេទ្យកុមារជាតិ។

**១. ក្រុមអាហារពណ៌លឿង**

ជាអាហារថាមពល ផ្តល់នូវកម្លាំងសម្រាប់ធ្វើសកម្មភាព។ អាហារទាំងនោះមាន បាយ មី  មីសួរ គុយទាវ អំបុក ពោតនំ ស្ករ ដំឡូងបារាំង ត្រាវ ដំបូងថ្វា ដំឡូងឈើ អំពៅ ទឹកឃ្មុំ ប្រេងឆា ខ្ទិះដូង។

**២. ក្រុមអាហារពណ៌ក្រហម**

ជាអាហារសាងសង់ ឬស្ថាបនារាងកាយ ជួយឱ្យរាងកាយលូតលាស់ទ្រទ្រង់ ថែរក្សា និងជួសជុលជាលិការបស់រាងកាយ និងជួយបង្កើតសាច់ដុំ ឈាម និងឆ្អឹង។ អាហារក្រុមពណ៌ក្រហមមានដូចជា សាច់គោ សាច់ជ្រូក សាច់មាន់ ថ្លើម មឹក បង្កង បង្គា កំពឹស ក្តាមខ្យង កង្កែប ត្រីងៀត ត្រីឆ្អើរ ស៊ុត សាច់ក្រក តៅហ៊ូ ទឹកសណ្តែក សណ្តែកសៀង សណ្តែកបាយ សណ្តែកដី ជាដើម។



**៣. ក្រុមអាហារពណ៌បៃតង**

ជាអាហារការពាររាងកាយ មានតួនាទីពង្រឹងមុខងាររបស់រាងកាយ និងការពាររាងកាយទប់ទល់ជំងឺ និងការបង្ករោគផ្សេងៗ។អាហារក្រុមពណ៌បៃតងរួមមាន ល្ពៅ ប៉េងប៉ោះ ការ៉ុត ក្រូច ល្មុត សណ្តែកកួរ ស្ពៃក្តោប ឪឡឹក ត្របែក ននោង ត្រឡាច ត្រយូងចេក ខ្នុរ ចេក ត្រសក់ ត្រប់ ល្ហុង ម្នាស់ ត្រកួន ស្លឹកម្រុំ ស្លឹកបាស ត្រួយល្ពៅ ជាដើម៕



ប្រភព៖https://hellokrupet.com/



# កម្រងពាក្យអប់រំ ដកស្រង់ពីព្រះពុទ្ធសាសនា
## ប្រមូលរៀបរៀងដោយ ភិក្ខុ វជិរប្បញ្ញោ គូ សុភាព

**មាតាបិតាល្អ**

ហាមកូនមិនឱ្យធ្វើអាក្រក់ នាំកូនធ្វើតែអំពើល្អ ឱ្យកូនរៀនសូត្រ រៀបចំគ្រួសារឱ្យកូន ចែកទ្រព្យសម្បត្តិតាមលទ្ធភាព។

**កូនល្អ**

មិនខ្ជិលច្រអូស ជួយធ្វើការងារឪពុកម្តាយ ចិញ្ចឹមបីបាច់ថែរក្សាគាត់ ថែរក្សាពូជពង្សវង្សត្រកូល ថែរក្សានិងប្រើប្រាស់កេរ្តិ៍មរតកឱ្យបានល្អ ធ្វើបុណ្យឧទ្ទិសជូនគាត់ ពេលគាត់ស្លាប់។

**គ្រូល្អ**

ដឹកនាំសិស្សក្នុងផ្លូវត្រូវ ចាត់ចែងការបង្រៀនឱ្យបានល្អ មិនលាក់ចំណេះ លើកទឹកចិត្តសិស្សល្អ ការពារសិស្សពីអន្តរាយ។

**សិស្សល្អ**

គោរពគ្រូដោយសេចក្តីកោតក្រែង បំពេញកិច្ចការ ដោយយកចិត្តទុកដាក់ ត្រង់ត្រាបស្តាប់ឱវាទ ជួយកិច្ចការគ្រូ រៀនដោយយកចិត្តទុកដាក់។

**មេល្អ**

ចាត់ចែងការងារតាមសមត្ថភាព ផ្តល់ប្រាក់ខែសមរម្យ ឱ្យឈប់សម្រាក់តាមកាលគួរ ផ្តល់ប្រាក់រង្វាន់បន្ថែម ផ្តល់សុវត្ថិភាពការងារ និងជួយមើលជំងឺ។

**បុគ្គលិកល្អ**

ចូលធ្វើការមុនមេ ចេញក្រោយមេ ស្មោះត្រង់ មិនខ្ជិលច្រអូស និយាយល្អពីមេ និងស្ថាប័ន។

**អ្នកបួសល្អ**

ណែនាំពុទ្ធបរិស័ទមិនឱ្យធ្វើអាក្រក់ ដឹកនាំឱ្យធ្វើតែអំពើល្អ ពន្យល់ណែនាំធម៌ល្អៗ រាប់អានដោយចិត្តស្មោះស ប្រាប់ហេតុនៃសេចក្តីសុខបច្ចុប្បន្ននិងអនាគត។

**ពុទ្ធបរិស័ទល្អ**

គោរពឱនលំទោនចំពោះព្រះសង្ឃ ប្រើពាក្យសម្តីសមរម្យ មានបំណងល្អ មិនបិទទ្វារផ្ទះ ចេះធ្វើទានដល់ព្រះសង្ឃ៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

**MINISTRY OF INFORMATION**

លេខ :....៥០៤.........ព.មប្រក

ថ្ងៃ.ចន្ទ ៩កើត... ខែ.អស្សុជ..... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..០៧.....ខែ.តុលា......ឆ្នាំ២០១៩

# ប្រកាស

# រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦/០៩/១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨/០៦/១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ /០៩/៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៤ ចុះថ្ងៃទី២៤ /០១/៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.បក ចុះថ្ងៃទី០៥/០៨/៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣/០៧/០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងប្រកាសរបស់ក្រសួងព័ត៌មានលេខ ៦២៥/០៩ ព.ម ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ "បេឡាជាតិរបបសន្តិសុខសង្គម" ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ។
- យោងលិខិតស្នើសុំផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់លោក ជាវ ប៊ុនរិទ្ធ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឲ្យផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ពីលោក ជាវ ប៊ុនរិទ្ធ មកលោក ហេង សុផាន់ណារិទ្ធ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៨៦៨២៨២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ មានអាសយដ្ឋាននៅផ្ទះ៧៣AE0E1 ផ្លូវ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជំនួសវិញ ៖

-មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពី របបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាសយដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និងឈ្មោះអាសយដ្ឋានរោងពុម្ពនៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន និងចំនួន០២ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ។

**ប្រការ៣** : ករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤** : ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ខុទ្ទកាល័យ នៃក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងព័ត៌មាន

**ខៀវ កាញារីទ្ធ**

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ)
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មាន
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិរបបសន្តិសុខសង្គម
NSSF Official
www.nssf.gov.kh
info@nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
( បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

